របាយការណ៍ព័ត៌មានអំពីវ៉ាក់សាំង

# វ៉ាក់សាំង MMR (កញ្ជ្រឹល ស្រឡទែន និងកញ្ជ្រឹលស្រាល)៖ *តើលោកអ្នកត្រូវការយល់ដឹងអ្វីខ្លះ*

របាយការណ៍ព័ត៌មានអំពីវ៉ាក់សាំងជាច្រើន អាចមានជាភាសាអេស្ប៉ាញនិងភាសាផ្សេងទៀត។ សូមមើលវិបសាយ www.immunize.org/vis

Hojas de información sobre vacunas están disponibles en español y en muchos otros idiomas. សូមចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវការចាក់វ៉ាក់សាំង?

**វ៉ាក់សាំង MMR** អាចការពារ **កញ្ជ្រឹល ស្រឡទែន** និង**កញ្ជ្រឹលស្រាល**៖

- **កញ្ជ្រឹល MEASLES (M)** បណ្ដាលឱ្យមានគ្រុនក្ដៅខ្លួន ក្អក ហៀរសំបោរ និងក្រហមលើស្បែក ភ្នែករលីងរលោង ដែលជាទូទៅកើតឡើងដោយកន្ទួលលើស្បែកដែលគ្របដណ្ដប់លើរាងកាយទាំងមូល។ វាអាចនាំឱ្យប្រកាច់ (ជាញឹកញាប់ទាក់ទងនឹងគ្រុនក្ដៅខ្លួន) ការឆ្លងមេរោគត្រចៀក រាគ និងជំងឺរលាកសួត។ កម្រណាស់ដែលកញ្ជ្រឹលអាចបណ្ដាលឱ្យខូចខួរក្បាល ឬស្លាប់។
- **ស្រឡទែន MUMPS (M)** បណ្ដាលឱ្យមានគ្រុនក្ដៅខ្លួន ឈឺក្បាល ឈឺសាច់ដុំ អស់កម្លាំង បាត់បង់ចំណង់អាហារ និងហើម និងក្រពេញទឹកមាត់ភ្លន់នៅក្រោមត្រចៀក។ វាអាចបណ្ដាលឱ្យថ្លង់ ហើមខួរក្បាល និង/ឬ ការគ្របណ្ដប់ខួរឆ្អឹងខ្នង ការហើមឈឺចាប់ពងស្វាស ឬអូវែរ ហើយកម្រកើតមានណាស់ គឺការស្លាប់។
- **កញ្ជ្រឹលស្រាល RUBELLA (R)** បណ្ដាលឱ្យមានគ្រុនក្ដៅខ្លួន ឈឺបំពង់ក កន្ទួលលើស្បែក ឈឺក្បាល និងរលាកភ្នែក។ វាអាចបណ្ដាលឱ្យរលាកសន្លាក់រហូតដល់ពាក់កណ្ដាលនៃស្ត្រីជំទង់ និងស្ត្រីពេញវ័យ។ ប្រសិនបើមនុស្សម្នាក់កើតជំងឺកញ្ជ្រឹលស្រាលនៅខណៈពេលដែលពួកគេមានផ្ទៃពោះ ពួកគេអាចរលូតកូន ឬទារកអាចកើតមកមានពិការភាពពីកំណើតធ្ងន់ធ្ងរ។

មនុស្សភាគច្រើនដែលបានចាក់វ៉ាក់សាំង MMR នឹងត្រូវបានការពារអស់មួយជីវិត។ វ៉ាក់សាំង និងអត្រាចាក់វ៉ាក់សាំងបង្ការកម្រិតខ្ពស់ បានធ្វើឱ្យជំងឺទាំងនេះ មិនសូវមានជំងឺឆ្លងជាទូទៅនៅសហរដ្ឋអាមេរិក។

## 2. វ៉ាក់សាំង MMR

តាមធម្មតា **កុមារ**ត្រូវការវ៉ាក់សាំង MMR ចំនួន 2 ដូស៖

- ដូសទីមួយ នៅអាយុ 12 ទៅ 15 ខែ
- ដូសទីពីរ នៅអាយុ 4 ទៅ 6 ឆ្នាំ

**ទារកដែលនឹងធ្វើដំណើរទៅក្រៅសហរដ្ឋអាមេរិកនៅពេលដែលពួកគេមានអាយុចន្លោះពី 6 ទៅ 11 ខែ** គួរចាក់វ៉ាក់សាំង MMR មុនពេលធ្វើដំណើរ។ កុមារទាំងនេះ នៅតែត្រូវចាក់វ៉ាក់សាំង 2 ដូសបន្ថែមនៅអាយុដែលបានណែនាំ សម្រាប់ការការពារយូរអង្វែង។

**ក្មេងធំ ក្មេងជំទង់** និង**មនុស្សពេញវ័យ** ក៏ត្រូវការចាក់វ៉ាក់សាំង MMR ចំនួន 1 ឬ 2 ដូសផងដែរ ប្រសិនបើពួកគេមិនទាន់បានចាក់វ៉ាក់សាំង ភាពស៊ាំនឹងជំងឺកញ្ជ្រឹល ស្រឡទែន និងកញ្ជ្រឹលស្រាល។ អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក អាចជួយលោកអ្នកកំណត់កម្រិតដូសថ្នាំប៉ុន្មានដែលលោកអ្នកត្រូវការ។

កម្រិតដូសទីបីនៃវ៉ាក់សាំង MMR អាចត្រូវបានណែនាំសម្រាប់មនុស្សមួយចំនួនដែលមានបញ្ហារីករាលដាលជំងឺស្រឡទែន។

វ៉ាក់សាំង MMR អាចចាក់នៅពេលដំណាលគ្នានឹងវ៉ាក់សាំងផ្សេងទៀត។ កុមារដែលមានអាយុពី 12 ខែ ដល់ 12 ឆ្នាំ អាចចាក់វ៉ាក់សាំង MMR រួមគ្នាជាមួយនឹងវ៉ាក់សាំងអុតស្វាយដែលចាក់តែមួយដង ដែលគេស្គាល់ថាវ៉ាក់សាំង MMRV។ អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក អាចផ្ដល់ជូនលោកអ្នកនូវព័ត៌មានបន្ថែម។

## 3. សូមពិភាក្សាជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក។

សូមប្រាប់អ្នកផ្ដល់សេវាចាក់វ៉ាក់សាំងបង្ការរបស់អ្នក ប្រសិនបើលោកអ្នកចាក់វ៉ាក់សាំងបង្ការ៖

- មានមាន**ប្រតិកម្មអាល់ឡែហ្ស៊ី បន្ទាប់ពីការចាក់វ៉ាក់សាំងដូស MMR ឬ MMRV ពីមុន ឬមានអាល់ឡែហ្ស៊ីធ្ងន់ធ្ងរណាមួយដែលគំរាមកំហែងដល់អាយុជីវិត**
- មាន**ផ្ទៃពោះ** ឬគិតថាពួកគេប្រហែលជាអាចមានផ្ទៃពោះ — អ្នកមានផ្ទៃពោះមិនគួរចាក់វ៉ាក់សាំង MMR ទេ
- មាន**ប្រព័ន្ធការពាររាងកាយចុះខ្សោយ** ឬមាន**ឳពុកឬម្ដាយ បងប្អូន ឬបងប្អូនស្រីដែលមានប្រវត្តិបញ្ហាប្រព័ន្ធការពាររាងកាយពីកំណើតឬតំណពូជ**
- ធ្លាប់មាន**បញ្ហាដែលធ្វើឱ្យគាត់មានស្នាមជាំ ឬហូរឈាមយ៉ាងងាយ**
- នាពេលថ្មីៗនេះ **បានបញ្ចូលឈាម ឬបានទទួលផលិតផលឈាមផ្សេងទៀត**
- មាន**ជំងឺរបេង**
- បាន**ចាក់វ៉ាក់សាំងផ្សេងទៀតក្នុងរយៈពេល 4 សប្ដាហ៍កន្លងមកនេះ**

ក្នុងករណីខ្លះ អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក អាចសម្រេចចិត្តពន្យាពេលការចាក់វ៉ាក់សាំង MMR រហូតដល់ការទៅជួបពិនិត្យនាពេលខាងមុខ។



ក្រសួងសុខាភិបាល និងសេវាពលរដ្ឋ នៃសហរដ្ឋអាមេរិក
មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ

អ្នកដែលមានជំងឺកម្រិតស្រាល ដូចជាផ្ដាសាយ អាចចាក់វ៉ាក់សាំងបាន។ អ្នកដែលឈឺកម្រិតមធ្យម ឬធ្ងន់ធ្ងរ តាមធម្មតាត្រូវរង់ចាំរហូតដល់ពួកគេជាសះស្បើយឡើងវិញ មុនពេលចាក់វ៉ាក់សាំង MMR។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក អាចផ្តល់ជូនលោកអ្នកនូវព័ត៌មានបន្ថែម។

## 4. ហានិភ័យនៃប្រតិកម្មវ៉ាក់សាំងបង្ការ

- ឈឺដៃដោយសារការចាក់ថ្នាំ ឬឡើងក្រហមនៅកន្លែងចាក់ថ្នាំ គ្រុនក្តៅខ្លួន និងកន្ទួលស្រាល អាចកើតឡើងបន្ទាប់ពីចាក់វ៉ាក់សាំង MMR។
- ការហើមក្រពេញនៅថ្ពាល់ ឬក ឬការឈឺចាប់បណ្តោះអាសន្ន និងរឹងក្នុងសន្លាក់ (ភាគច្រើនចំពោះស្ត្រីវ័យជំទង់ ឬមនុស្សពេញវ័យ) ជួនកាលកើតឡើងបន្ទាប់ពីការចាក់វ៉ាក់សាំង MMR។
- ប្រតិកម្មអាល់ឡែហ្ស៊ីធ្ងន់ធ្ងរថែមទៀត កើតឡើងដោយកម្រ។ ទាំងនេះអាចរួមបញ្ចូលការប្រកាច់ (ជាញឹកញាប់ទាក់ទងនឹងគ្រុនក្តៅខ្លួន) ការគណនាគោសិកាគ្មានអេម៉ូក្លូប៊ីនរាងសំប៉ែតកម្រិតទាបបណ្តោះអាសន្ន ដែលអាចបណ្តាលឱ្យមានការហូរឈាម ឬស្នាមជាំខុសពីធម្មតា។
- ចំពោះអ្នកដែលមានបញ្ហាប្រព័ន្ធភាពស៊ាំរាងកាយធ្ងន់ធ្ងរ វ៉ាក់សាំងនេះអាចបណ្តាលឱ្យមានការឆ្លងមេរោគដែលអាចមានគំរាមកំហែងដល់អាយុជីវិត។ អ្នកដែលមានបញ្ហាប្រព័ន្ធភាពស៊ាំរាងកាយធ្ងន់ធ្ងរ មិនត្រូវចាក់វ៉ាក់សាំង MMR ទេ។

ពេលខ្លះមនុស្សដួលសន្លប់បន្ទាប់ពីដំណើរការផ្នែកវេជ្ជសាស្ត្រ រួមទាំងការចាក់វ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវារបស់អ្នក ប្រសិនបើលោកអ្នកមានអារម្មណ៍វិលមុខ ឬមានការផ្លាស់ប្តូរការមើលឃើញ ឬឮសូរសម្លេងនៅ
ក្នុងត្រចៀក។

ដូចគ្នាទៅនឹងថ្នាំណាមួយផងដែរ វ៉ាក់សាំងមានឱកាសតិចតួចណាស់ដែលបង្កឱ្យមានប្រតិកម្មអាល់ឡែហ្ស៊ីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេងទៀត ឬស្លាប់។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាល់ឡែហ្ស៊ីអាចេកីតេឡីងបន្ទាប់ពីលោកអ្នកចាក់វ៉ា ក់សាំងបង្ការចាកេចញពីគ្លីនិក។
ប្រសិនបើលោកអ្នកេឃីញសញ្ញ ប្រតិកម្មអាល់ឡែហ្ស៊ីធ្ងន់ធ្ងរ (កន្ទួលលើស្បែក ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម េបះដូងលោតញាប់ វិ លមុខ ឬខ្សោយ) សូមេហៅទូរស័ព្ទទៅលេខ 9-1-1 ហើយនាំអ្នកជំងឺទៅមន្ទីរពេទ្យដែលេនៅជិតបំផុត។

សម្រាប់សញ្ញ ផ្សេងទៀតែដលទាក់ទងនឹងលោកអ្នក សូមេហៅទូរស័ព្ទទៅអ្នកផ្តល់សេវាែថទាំសុខភាពរបស់អ្នក។

សូមរាយការណ៍ប្រតិកម្មមិនល្អទៅប្រព័ន្ធរាយការណ៍ពីចំណុចមិនល្អនៃវ៉ាក់សាំង (VAERS)។ តាមធម្មតាអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកនឹងដាក់របាយការណ៍នេះ ឬលោកអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលមើលវិបសាយ VAERS តាម www.vaers.hhs.gov ឬហៅទូរស័ព្ទលេខ 1-800-822-7967. *ប្រព័ន្ធរាយការណ៍ VAERS គឺសម្រាប់រាយការណ៍ពីប្រតិកម្មតែប៉ុណ្ណោះ ហើយសមាជិកនៃបុគ្គលិក VAERS មិនផ្តល់ជូនការណែនាំផ្នែកវេជ្ជសាស្ត្រទេ។*

## 6. កម្មវិធីសំណងរបួសស្នាមដោយវ៉ាក់សាំងបង្ការថ្នាក់ជាតិ

កម្មវិធីសំណងរបួសស្នាមដោយវ៉ាក់សាំងបង្ការថ្នាក់ជាតិ (VICP) គឺជាកម្មវិធីរបស់សហព័ន្ធដែលបានបង្កើតឡើង ដើម្បីផ្តល់ជូនសំណងដល់ប្រជាពលរដ្ឋដែលអាចរងរបួសដោយសារវ៉ាក់សាំងមួយចំនួន។ បណ្តឹងទាមទារទាក់ទងនឹងរបួស ឬការស្លាប់ដោយសារការចាក់វ៉ាក់សាំង មានពេលកំណត់សម្រាប់ការដាក់ឯកសារ ដែលអាចមានរយៈពេលខ្លីរហូតដល់ពីរឆ្នាំ។ សូមចូលទៅគេហទំព័រ VICP តាម www.hrsa.gov/vaccinecompensation ឬហៅទូរស័ព្ទលេខ 1-800-338-2382 ដើម្បីស្វែងយល់អំពីកម្មវិធី និងការដាក់ឯកសារបណ្តឹងទាមទារ។

## 7. តើខ្ញុំអាចស្វែងយល់បន្ថែមដោយរបៀបណា?

- សូមសាកសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- សូមហៅទូរស័ព្ទទៅនាយកដ្ឋានសុខាភិបាលនៅមូលដ្ឋាន ឬរដ្ឋរបស់អ្នក។
- សូមចូលទៅគេហទំព័ររដ្ឋបាលចំណីអាហារនិងឱសថ (FDA) សម្រាប់ការបញ្ចូលកញ្ចប់វ៉ាក់សាំង និងព័ត៌មានបន្ថែមតាម www.fda.gov/vaccines-blood-biologics/vaccines.
- សូមទាក់ទងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ (CDC)៖
  -សូមហៅទូរស័ព្ទលេខ 1-800-232-4636 (1-800-CDC-INFO) ឬ
  -សូមចូលមើលវិបសាយ CDC តាម **www.cdc.gov.vaccines**.

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណៈត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ព័ត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។

DCH-0454CA | AUTH: P. H. S., Act 42, Sect. 2126.

របាយការណ៍ព័ត៌មានអំពីវ៉ាក់សាំង
វ៉ាក់សាំង MMR

42 U.S.C. § 300aa-26
8/6/2021

ការិយាល័យប្រើប្រាស់តែប៉ុណ្ណោះ